# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ :** ០៧៣/១៥ **ក.ប**/ស.ស.រ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតលេខាធិការដ្ឋានរបស់ក្រុមការងារសម្រាប់ទទួលបន្ទុកអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងសេចក្តីសម្រេចលេខ ០១៦/១៥ក.ប/ស.ស.រ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការបង្កើតក្រុមការងារសម្រាប់ទទួលទទួលបន្ទុកអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ក្នុងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងស្មារតីកិច្ចប្រជុំថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតលេខាធិការដ្ឋានរបស់ក្រុមការងារសម្រាប់ទទួលបន្ទុកអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម **ហេង សួរ** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | | ប្រធាន |
| ២-ឯកឧត្តម **ឡៅ ហ៊ីម** | អគ្គនាយកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | | អនុប្រធាន |
| ៣-ឯកឧត្តម **សេង សក្ដា** | អគ្គនាយកការងារ | | អនុប្រធាន |
| ៤-ឯកឧត្តម **ហុង ជឿន** | ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ | | អនុប្រធាន |

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

| | | | |
|---|---|---|---|
| ៥-លោក | **អ៊ុក សមវិទ្យា** | នាយកបេឡាជាតិរបបសន្តិសុខសង្គម | អនុប្រធាន |
| ៦-លោក | **តឹប រឿន** | អគ្គនាយករងអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | សមាជិកអចិន្ត្រៃយ៍ |
| ៧-លោក | **អ៊ិន ខេមរា** | អគ្គនាយករងការងារ | សមាជិក |
| ៨-កញ្ញា | **បញ្ញា សុម៉ូនិច** | ទីប្រឹក្សាអមក្រសួង | សមាជិក |
| ៩-លោក | **ឃិន ចន្ថា** | ប្រធាននាយកដ្ឋានគ្រប់គ្រងគ្រឹះស្ថានសិក្សា | សមាជិក |
| ១០-លោក | **សុភខុន ដាវីដ** | ប្រធាននាយកដ្ឋានធានាគុណភាព | សមាជិក |
| ១១-លោក | **ហ៊ីង ស៊ីដេត** | ប្រធាននាយកដ្ឋានបណ្តុះបណ្តាល | សមាជិក |
| ១២-លោកស្រី | **នង កណ្ណិកា** | ប្រធាននាយកដ្ឋានគោលនយោបាយ និងយុទ្ធសាស្ត្រ | សមាជិកា |
| ១៣-លោក | **ឆាង សាក់** | ប្រធាននាយកដ្ឋានស្តង់ដា និងកម្មវិធីសិក្សា | សមាជិក |
| ១៤-លោកស្រី | **សៅ សុគន្ធកេត្យា** | ប្រធាននាយកដ្ឋានព័ត៌មានទីផ្សារការងារ | សមាជិកា |
| ១៥-លោក | **អ៊ុក ចាន់ធូ** | ប្រធាននាយកដ្ឋានអធិការកិច្ចការងារ | សមាជិក |
| ១៦-លោក | **ឆាយ សុភា** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងគ្រឹះស្ថានសិក្សា | សមាជិក |
| ១៧-លោក | **សា ភិន្ទវីឌី** | អនុប្រធាននាយកដ្ឋានគោលនយោបាយ និងយុទ្ធសាស្ត្រ | សមាជិក |
| ១៨-លោក | **ទូច ពណ្ណរាយ** | អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម | សមាជិក |
| ១៩-លោក | **អ៊ុក សំសុវត្យា** | ប្រធានការិ.នៃនាយកដ្ឋានគោលនយោបាយ និងយុទ្ធសាស្ត្រ | សមាជិក |
| ២០-លោក | **ឈុំ ម៉ូរ៉ាត** | អនុប្រធានការិ.នៃនាយកដ្ឋានគោលនយោបាយ និងយុទ្ធសាស្ត្រ | សមាជិក |

**ប្រការ២.-**

លេខាធិការដ្ឋានរបស់ក្រុមការងារសម្រាប់ទទួលបន្ទុកអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ មានភារកិច្ចដូចខាងក្រោម៖

- រៀបចំកិច្ចប្រជុំប្រចាំខែ ដើម្បីពិនិត្យ ចងក្រងរបាយការណ៍អនុវត្តភារកិច្ចរបស់គ្រប់អង្គភាពពាក់ព័ន្ធ
- រៀបចំបូកសរុបលទ្ធផលនៃកិច្ចប្រជុំ និងសរសេររបាយការណ៍ដាក់ជូនឯកឧត្តមប្រធានក្រុមការងារ និងសមាជិក ដើម្បីពិនិត្យ និងសម្រេចសម្របសម្រួលជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីអនុវត្តការងាររបស់ក្រុមការងារឱ្យមានប្រសិទ្ធភាព
- អនុវត្តភារកិច្ចចាំបាច់ផ្សេងៗទៀតដែលឯកឧត្តមប្រធានក្រុមការងារប្រគល់ជូន។

**ប្រការ៣.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ នាយកបេឡាជាតិរបបសន្តិសុខសង្គម គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ៣ ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

***ចម្លងជូន៖***

-ថ្នាក់ដឹកនាំទទួលបន្ទុក
"ដើម្បីជូនជ្រាប"
-ដូចប្រការ ៣
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ